# សេចក្ដីថ្លែងការណ៍របស់សហគមន៍ស្ដីពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី
# នៅតាមដងទន្លេស្រែពកក្នុងប្រទេសវៀតណាម

**ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧**

**សណ្ឋាគារសាន់វេ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

យើងខ្ញុំជាប្រជាពលរដ្ឋចំនួន ១១.០០០នាក់ ដែលរស់នៅតាមដងទន្លេស្រែពក កំពុងតែជួបប្រទះ និងមានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើផលប៉ះពាល់ និងផែនការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើនៃអាងទន្លេស្រែពកក្នុងប្រទេសវៀតណាម។

យើងខ្ញុំតំណាងឱ្យសហគមន៍ទាំងអស់នៃទន្លេស្រែពក មានសេចក្តីរីករាយយ៉ាងខ្លាំង ដោយត្រូវបានគ្រប់ភាគីអ្នកពាក់ព័ន្ធផ្តល់ឱកាសឱ្យចូលរួមនៅក្នុង "កិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានមកលើកម្ពុជា ដែលបណ្តាលមកពីគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីរបស់វៀតណាមមកលើទន្លេស្រែពក"។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមលើកឡើងនូវបញ្ហាផលប៉ះពាល់មកលើការរស់នៅ និងជីវភាពរបស់យើងខ្ញុំដូចខាងក្រោម:

- ទឹកឡើងចុះមិនទៀងទាត់, ទន្លេ និងអន្លង់រាក់, បាក់ច្រាំងទន្លេ
- គុណភាពទឹកមិនល្អ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ
- ទឹកជំនន់ធ្វើឱ្យលិចស្រែ ចំការ បណ្តាលឱ្យខូចខាតផលដំណាំ និងបាត់បង់ទ្រព្យសម្បត្តិ
- បោះបង់ដីស្រែនៅជិតទន្លេ ដែលធ្វើឱ្យប្រជាពលរដ្ឋបង្ខំចិត្តទៅធ្វើកម្មករ និងចំណាយពេលវេលាយូរ ដើម្បីទៅរកស្បៀងនៅទីឆ្ងាយ
- ធនធានជលផលមានការថយចុះ ដែលធ្វើឱ្យអ្នកនេសាទបាត់បង់មុខរបរ
- ប៉ះពាល់ដល់ប្រពៃណីទំនៀមទំលាប់របស់ប្រជាជន

យោងទៅលើបញ្ហាដែលយើងខ្ញុំបានជួបប្រទះខាងលើនេះ យើងខ្ញុំសូមធ្វើសំណូមពរដូចតទៅ:

- សូមស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ធ្វើការដោះស្រាយរាល់បញ្ហាខាងលើ
- សូមកុំអោយសាងសង់ទំនប់វារីអគ្គិសនីបន្តទៀតនៅក្នុងទន្លេស្រែពក
- សូមឱ្យម្ចាស់ទំនប់ធ្វើការធានាដល់អាយុជីវិតប្រជាជន និងសងរាល់ការខូចខាតទាំងអតីតកាល បច្ចុប្បន្ន និងអនាគត
- សូមម្ចាស់ជំនួយបញ្ឈប់ការផ្តល់ជំនួយសំរាប់ផែនការសាងសង់ទំនប់វារីអគ្គិសនី ប្រសិនជាគ្មានដំណើរការអភិបាលកិច្ចល្អទៅលើសង្គម និងបរិស្ថាន
- សូមអោយរៀបចំប្រពន្ធ័ជូនដំណឹងដល់សហគមន៍ និងបែងចែកផលប្រយោជន៍ដែលទទួលបានពីគំរោងអភិវឌ្ឍន៍ទាំងនេះ

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា រាល់បញ្ហាដែលបានលើកឡើងខាងលើនេះ ត្រូវបានគ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងទទួលយកទៅពិចារណា និងធ្វើការដោះស្រាយជូនដល់យើងខ្ញុំដោយសមស្រប និងអាចទទួលយកបានទាំងអស់គ្នា។

**ពីតំណាងសហគមន៍ទន្លេស្រែពក!**